ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល

លេខ ៤៤ អនក្រ                                             10 . សីហា 1994

# អនុក្រឹត្យ

## ស្តីពី

## ទិដ្ឋាការ-បញ្ជិកាឱសថ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សំរេច

មាត្រា១: ឱសថគ្រប់ប្រភេទដែលផលិតក្នុងប្រទេសអាចតាំងលក់បាន លុះត្រាតែមានចុះលេខទិដ្ឋាការយល់ព្រមពីក្រសួងសុខាភិបាល ។

មាត្រា២: ឱសថគ្រប់ប្រភេទដែលនាំចូលពីបរទេស អាចតាំងលក់បានលុះត្រាតែមានចុះលេខបញ្ជិកាយល់ព្រមពីក្រសួងសុខាភិបាល ។

មាត្រា៣: លក្ខខ័ណ្ឌក្នុងការសុំលេខទិដ្ឋាការ-បញ្ជិកាឱសថ ត្រូវកំណត់ដោយក្រសួងសុខាភិបាល ។

មាត្រា៤: ឱសថដែលបានទទួលលេខទិដ្ឋាការ ឬ បញ្ជិកាឱសថពីក្រសួងសុខាភិបាល ត្រូវបង់សោហ៊ុយតាមការកំណត់របស់ក្រសួងសុខាភិបាល ។

មាត្រា៥: ការត្រួតពិនិត្យការផ្តល់ និង ការដកហូតវិញ នូវ លេខទិដ្ឋាការ ឬ បញ្ជិកាឱសថជាសមត្ថកិច្ចរបស់ក្រសួង សុខាភិបាល ។

មាត្រា៦: បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៧: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានភារកិច្ចអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពតាមភារកិច្ចរៀង ៗ ខ្លួន ។

មាត្រា៨: អនុក្រឹត្យនេះមានអានុភាពជាគតិយុត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។៕

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែ សីហា ឆ្នាំ ១៩៩៤

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

ចម្លងជូន:

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រីទី ២

-ដូចប្រការ ៧

-ឯកសារ-កាលប្បវត្តិ